STATE OF WASHINGTON
DEPARTMENT OF SOCIAL AND HEALTH SERVICES
DIVISION OF CHILD SUPPORT (DCS)

# បង្គនាលិខិតស្នើសុំការកែប្រែ – ដីការដ្ឋបាល

## Petition for Modification – Administrative Order

| | | |
|---|---|---|
| យោងតាម ៖ | ) | លេខសំណុំរឿង ៖ |
| ឪពុកឬម្ដាយមិនមែនជាអ្នកអាណាព្យាបាលកូន | ) | |
| | ) | |
| | ) | |
| ឪពុកឬម្ដាយជាអ្នកអាណាព្យាបាលកូន | ) | |

### សេចក្ដីណែនាំ

លើកលែងតែហត្ថលេខារបស់អ្នកមួយចេញ, ចូរសរសេរផ្ដង់ឲ្យច្បាស់ៗនូវគ្រប់សេចក្ដីឆ្លើយតបទាំងអស់។ ចូរប្រើតែប៊ិចពណ៌ខៀវ ឬពណ៌ខ្មៅ។

ក្រមរដ្ឋបាល WAC 388-14A-3925 តម្រូវឲ្យអ្នក ៖

1. ចុះចំនួនប្រាក់ឧបត្ថម្ភកូន(ថ្មី) ដែលបានស្នើ។
2. បញ្ជាក់អំពីមូលហេតុនៃការស្នើសុំការកែប្រែរបស់អ្នក។
3. ចុះហត្ថលេខាលើទម្រង់នេះ។

អ្នកត្រូវតែបំពេញឯកសារនានា ដែលបានចុះនៅលើទំព័រទី 2 នៃទម្រង់នេះ រួចហើយផ្ញើវាត្រឡប់ទៅ DCS វិញ។

**សូមកត់សម្គាល់ ៖** ប្រសិនបើអ្នកមិនបំពេញគ្រប់ចំណាត់ការដែលបានតម្រូវទាំងអស់ទេ, ចៅក្រមរដ្ឋបាល (Administrative Law Judge – ALJ) អាចនឹងលើកចោលនូវបង្គនាលិខិតនេះ។

### បង្គនាលិខិត

ខ្ញុំបាទ/នាងខ្ញុំ, ____________________________________________, ស្នើសុំការិយាល័យសវនាការរដ្ឋបាល (Office of Administrative Hearings – OAH) ផ្ដល់ការណែនាំដល់នាយកដ្ឋានឧបត្ថម្ភកុមារ (Division of Child Support – DCS) និងបណ្ដាភាគី ដែលមានឈ្មោះខាងលើ ឲ្យបង្ហាញខ្លួន និងបញ្ជាក់អំពីមូលហេតុថា ហេតុអ្វីបានជាដីកាឧបត្ថម្ភកូនរដ្ឋបាលរបស់ខ្ញុំមិនគួរត្រូវបានកែប្រែ។ ដីកាឧបត្ថម្ភកូនរដ្ឋបាលរបស់ខ្ញុំបានត្រូវចុះបញ្ជីកាលពី _____________។

ខ្ញុំជឿថា ចំនួនប្រាក់ឧបត្ថម្ភកូនបច្ចុប្បន្នសម្រាប់សំណុំរឿងនេះគួរតែមានចំនួន $________________ ក្នុងមួយខែ។

ខ្ញុំជឿថា ចំនួនប្រាក់ឧបត្ថម្ភកូនបច្ចុប្បន្ននេះគួរតែត្រូវបានកែប្រែ ពីព្រោះ ៖

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

**សូមអានមើលទំព័រទី 2 និងទី 3 សម្រាប់ស្វែងយល់ល័ក្ខខ័ណ្ឌតម្រូវនានាបន្ថែម និងសម្រាប់ផ្នែកនៃការចុះហត្ថលេខារបស់អ្នក។**

## ការទទួលស្គាល់

ខ្ញុំយល់ថា ៖

1. DCS នឹងជំទាស់នឹងបដ្ឋទាលិខិតនេះ ប្រសិនបើវាមិនស្របតាមលក្ខណវិនិច្ឆ័យសម្រាប់ការកែប្រែដីកា ដែលមានចែងក្នុង RCW 74.20A.059។
2. ប្រសិនបើដីការបស់ខ្ញុំឥឡូវនេះពុំមានផ្ទុកបទបញ្ញត្តិទាំងនេះទេ, នោះ DCS នឹងស្នើសុំចៅក្រម ALJ ឲ្យបញ្ចូលបទបញ្ញត្តិទាំងនេះក្នុងដីការបស់ខ្ញុំ ដើម្បីតម្រូវឲ្យឪពុកម្តាយម្នាក់ៗផ្តល់កម្រៃធានារ៉ាប់រងសុខភាពសម្រាប់កូន(ៗ) ប្រសិនបើកម្រៃរ៉ាប់រងនេះកំពុងមាន ឬនឹងមានបម្រើការតាមរយៈនិយោជក ឬសហជីពការងារ ហើយតម្លៃនៃការបង់បុព្វលាភធានារ៉ាប់សុខភាពនេះមិនលើសពី 25 ភាគរយនៃកាតព្វកិច្ចឧបត្ថម្ភជាមូលដ្ឋានរបស់ឪពុកឬម្តាយម្នាក់ៗទេនោះ។ DCS នឹងចាត់ទុកថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញ ប្រសិនបើកូន(ៗ)មានលក្ខណសម្បត្តិទទួលសេវាសុខភាពឥណ្ឌាន (Indian Health Services)។ DCS អាចនឹងអនុវត្តកាតព្វកិច្ចនេះនៅក្រោមស្ថានភាពជាក់លាក់។ ឪពុកឬម្តាយដែលជាប់កាតព្វកិច្ចត្រូវតែបង្ហាញភ័ស្តុតាងអំពីកម្រៃរ៉ាប់រង ដែលអាចប្រើប្រាស់បានសម្រាប់កូន(ៗ) ដល់ DCS និងឪពុកឬម្តាយម្ខាងទៀតក្នុងរយៈពេល 20 ថ្ងៃ ចាប់ពីកាលបរិច្ឆេទ ដែលដីកាឧបត្ថម្ភកូនអវសានត្រូវបានចុះបញ្ជី។ ប្រសិនបើឪពុកឬម្តាយជាប់កាតព្វកិច្ចមិនបង្ហាញភ័ស្តុតាងអំពីកម្រៃរ៉ាប់រងទេ, នោះគេអាចនឹងតម្រូវឲ្យឪពុកឬម្តាយជាប់កាតព្វកិច្ច បំពេញកាតព្វកិច្ចខ្លួនតាមរយៈការផ្តល់ការធានារ៉ាប់រងសុខភាព ដោយបំពេញករណីមួយក្នុងចំណោមករណីនានាខាងក្រោមនេះ, ទៅតាមលំដាប់អាទិភាព ៖
    a. ផ្តល់ ឬរក្សាការផ្តល់កម្រៃធានារ៉ាប់រងសុខភាពតាមរយៈនិយោជក ឬសហជីពការងាររបស់ឪពុកឬម្តាយជាប់កាតព្វកិច្ច ក្នុងតម្លៃដែលមិន លើសពី 25 ភាគរយនៃកាតព្វកិច្ចឧបត្ថម្ភកូនជាមូលដ្ឋានរបស់ឪពុកឬម្តាយជាប់កាតព្វកិច្ច។
    b. បង់វិភាគទានទៅតាមចំណែកសមាមាត្រ(ស្មើភាគគ្នា)របស់ឪពុកឬម្តាយជាប់កាតព្វកិច្ច ដោយយោងទៅតាមតម្លៃបុព្វលាភធានារ៉ាប់រងសុខភាពប្រចាំខែ ដែលកំពុងបង់ដោយឪពុកឬម្តាយម្ខាងទៀតសម្រាប់កម្រៃធានារ៉ាប់រងសុខភាពចំពោះកូន(ៗ) ដែលមានឈ្មោះក្នុងដីកាឧបត្ថម្ភ នេះ, មិនឲ្យលើសពី 25 ភាគរយនៃកាតព្វកិច្ចឧបត្ថម្ភកូនជាមូលដ្ឋានរបស់ឪពុកឬម្តាយជាប់កាតព្វកិច្ចទេ។
3. ខ្ញុំត្រូវតែស្នើសុំការឧបត្ថម្ភកូនដោយមានការបញ្ជាក់ចំនួនប្រាក់ជាក់លាក់, ផ្តល់មូលហេតុសម្រាប់ការស្នើសុំការកែប្រែ, ហើយចុះហត្ថលេខាលើទម្រង់នេះ។ បើខ្ញុំមិនធ្វើដូច្នោះទេ, នោះ DCS មិនអាចធ្វើទិន្នន័យលើបដ្ឋទាលិខិតរបសខ្ញុំបានឡើយ។
4. ខ្ញុំត្រូវតែតម្កល់ឯកសារនានាខាងក្រោមនេះជាមួយ DCS។
    a. បដ្ឋទាលិខិតដែលបានបំពេញសព្វគ្រប់អន្លើនេះ។
    b. សន្លឹកកិច្ចការនៃ***បទដ្ឋានវិភាគប្រាក់ឧបត្ថម្ភកូននៃរដ្ឋវ៉ាស៊ីនតោន (Washington State Child Support Schedule)*** ដែលបានបំពេញសព្វគ្រប់អន្លើ។
    c. **បើខ្ញុំជាឪពុកឬម្តាយរបស់កូនៗទាំងនេះ**, នោះភ័ស្តុតាងប្រាក់ចំណូល (កន្ទុយសែកប្រាក់ខែ, ឯកសារពន្ធដារនិវត្តន៍ (tax returns) ។ល។)។
5. ខ្ញុំត្រូវតែផ្ញើឯកសារនានាខាងលើ ទៅកាន់អាសយដ្ឋានរបស់ ឬយកជូនដោយផ្ទាល់ដល់ការិយាល័យ DCS ជាក់លាក់មួយ ដែលកំពុងកាន់កាប់សំណុំរឿងរបស់ខ្ញុំ។

    DIVISION OF CHILD SUPPORT
    PO BOX 11520
    TACOMA WA 98411-5520

6. បើខ្ញុំមិនផ្តល់ឯកសារនានាខាងលើដល់ DCS ទេ, នោះចៅក្រម ALJ អាចនឹងលើកចោលនូវបដ្ឋទាលិខិតរបស់ខ្ញុំ។
7. ខ្ញុំត្រូវតែប្រាប់ DCS ប្រសិនបើខ្ញុំផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្ញុំ។
8. ខ្ញុំត្រូវតែប្រាប់ DCS ប្រសិនបើមានការផ្លាស់ប្តូរអ្វីមួយកើតឡើងដល់កម្រៃធានារ៉ាប់រងសុខភាពសម្រាប់កូនៗរបស់ខ្ញុំ។
9. DCS មិនតំណាងឲ្យរូបខ្ញុំ ឬឲ្យភាគីម្ខាងទៀតដែលមានឈ្មោះក្នុងដីកាឧបត្ថម្ភកូនរបស់ខ្ញុំ នៅក្នុងចំណាត់ការ(បណ្តឹង)នេះទេ។
10. ប្រសិនបើខ្ញុំមិនបង្ហាញខ្លួន និងមិនចូលរួមក្នុងសវនាការដែលបានកំណត់ណាមួយទេ, នោះចៅក្រម ALJ អាចនឹងលើកចោលនូវបដ្ឋទាលិខិតរបស់ខ្ញុំ។
11. ប្រសិនបើភាគីម្ខាងទៀតក្នុងដីការបស់ខ្ញុំ មិនបង្ហាញខ្លួន និងមិនចូលរួមក្នុងសវនាការដែលបានកំណត់ណាមួយទេ, នោះចៅក្រម ALJ អានឹង ៖
    a. ផ្តល់ការអនុញ្ញាតដល់សេចក្តីស្នើសុំរបស់ DCS ឬភាគីដែលបង្ហាញខ្លួនក្នុងករណីនេះ ដោយមិនចាំបាច់មានការជូនដំណឹងវែងឆ្ងាយទៀតឡើយ។
    b. ចេញដីកាកំណត់ប្រាក់ឧបត្ថម្ភក្នុងចំនួនណាមួយ ដែលអាចខ្ពស់ជាង ឬទាបជាងចំនួនដែលបានស្នើសុំក្នុងបដ្ឋទាលិខិតនេះ។

## សេចក្តីជូនដំណឹងដល់ឪពុកម្តាយទាំងសងខាង

ចៅក្រម ALJ អាចនឹង ៖

1. ចេញដីកាបញ្ជាឲ្យឪពុកម្តាយទាំងសងខាងផ្តល់ការធានារ៉ាប់រងសុខភាពដល់កូនៗ ប្រសិនបើកម្រៃរ៉ាប់ឥឡូវនេះកំពុងមាន ឬនឹងមានបម្រើការតាមរយៈនិយោជក ឬសហជីពការងាររបស់ខ្លួន ហើយតម្លៃនៃការបង់បុព្វលាភធានារ៉ាប់រងសុខភាពមិនលើសពី 25 ភាគរយនៃកាតព្វកិច្ចឧបត្ថម្ភកូនជាមូលដ្ឋានរបស់ឪពុកម្តាយទាំងសងខាងទៅនោះ។
2. ចេញដីកាបញ្ជាឲ្យឪពុកម្តាយទាំងសងខាងបង់ប្រាក់ក្នុងចំណែកសមាមាត្រ(ស្មើភាគគ្នា) ដើម្បីសងការចំណាយលើថ្លៃវេជ្ជសាស្ត្រ ដែលគ្មានការធានារ៉ាប់រង, ដោយសរុបទាំងការបង់ថ្លៃខ្វះភេយ៍ (copayments), ថ្លៃឪដាក់ចំបូល (deductibles), និងថ្លៃចំណែកសមាមាត្រនៃបុព្វលាភធានារ៉ាប់រងវេជ្ជសាស្ត្រ ដែលមិនបានត្រូវអនុវត្តតាមរយៈការប្រគល់ ***សេចក្តីជូនដំណឹងស្តីពីការឧបត្ថម្ភដែលបានជំពាក់* (Notice of Support Owed)** ទាទាផងៗ។
3. ចេញដីកាបញ្ជាថា បើឪពុកឬម្តាយម្នាក់ ដែលត្រូវបានបញ្ជាឲ្យផ្តល់កម្រៃធានារ៉ាប់រងសុខភាពសម្រាប់កូនៗ មិនផ្តល់ភស្តុតាងបញ្ជាក់ថា មានកម្រៃរ៉ាប់រងដែលអាចប្រើប្រាស់បានទេ, នោះ DCS មានសិទ្ធិអនុវត្តវិធានការមួយក្នុងចំណោមវិធានការទាទាខាងក្រោមនេះ, ទៅតាមលំដាប់អាទិភាព ៖
    a. ផ្ញើសេចក្តីជូនដំណឹងទៅនិយោជក ឬសហជីពការងារ ដើម្បីតម្រូវឲ្យនិយោជក ឬសហជីពការងារនោះ ចុះឈ្មោះកូនៗក្នុងផែនការធានារ៉ាប់រងសុខភាព ទៅតាមលក្ខខ័ណ្ឌនៃច្បាប់ដែលមានចែងក្នុងក្រមកំណែ RCW 28.18.170(8)។
    b. ប្រគល់សេចក្តីជូនដំណឹងដោយផ្ទាល់ទៅឪពុកឬម្តាយដែលជាប់កាតព្វកិច្ច ដើម្បីតម្រូវឪពុកឬម្តាយរូបនោះបង់ប្រាក់ចំណែកសមាមាត្ររបស់ខ្លួនទៅលើថ្លៃបុព្វលាភធានារ៉ាប់រងសុខភាពប្រចាំខែ ដែលកំពុងបង់ដោយឪពុកឬម្តាយម្ខាងទៀតសម្រាប់កូនៗ, មិនឲ្យលើសពី 25 ភាគរយនៃកាតព្វកិច្ចឧបត្ថម្ភកូនជាមូលដ្ឋានរបស់ឪពុកឬម្តាយដែលជាប់កាតព្វកិច្ចឡើយ;
4. ចេញដីកាបញ្ជាថា បើឪពុកឬម្តាយដែលជាប់កាតព្វកិច្ចខកខាន មិនបានចុះឈ្មោះកូនៗក្នុងផែនការកម្រៃធានារ៉ាប់រងសុខភាពដែលអាចប្រើប្រាស់ បាន, ឬកម្រៃរ៉ាប់រងដែលមានបម្រើការតាមរយៈនិយោជក ឬសហជីពការងាររបស់ឪពុកឬម្តាយរូបនោះទេ, នោះ DCS មានសិទ្ធិអាចអនុវត្តកាតព្វកិច្ចឧបត្ថម្ភវេជ្ជសាស្ត្ររបស់ឪពុកឬម្តាយដែលជាប់កាតព្វកិច្ច ទៅតាមលក្ខខ័ណ្ឌនៃច្បាប់ដែលមានចែងក្នុងក្រមកំណែ RCW 26.18.170 ។

## សេចក្តីប្រកាស

ខ្ញុំសូមប្រកាស, ក្រោមទោសបញ្ញត្តិនៃការបំពានសម្បថក្រោមច្បាប់នៃរដ្ឋវ៉ាស៊ីនតោន, ថា សេចក្តីរាយរាប់ខាងដើមនេះគឺសុទ្ធតែពិតប្រាកដ និងត្រឹមត្រូវ។

**អ្នកត្រូវតែចុះហត្ថលេខាលើទម្រង់នេះ**

| | |
|---|---|
| កាលបរិច្ឆេទ | ហត្ថលេខារបស់ខ្ញុំ |
| អាសយដ្ឋានប្រអប់សំបុត្រ ឬអាសយដ្ឋានផ្ទះ | ឈ្មោះរបស់មេធាវី ឬរបស់អ្នកតំណាងរបស់ខ្ញុំ |
| ក្រុងរបស់ខ្ញុំ / រដ្ឋ / លេខស៊ីបកូដ | អាសយដ្ឋានរបស់មេធាវី ឬរបស់អ្នកតំណាងរបស់ខ្ញុំ |
| ( ) លេខទូរស័ព្ទផ្ទះ / ( ) លេខទូរស័ព្ទដៃ | ក្រុង, រដ្ឋ, និងលេខស៊ីបកូដរបស់មេធាវី ឬរបស់អ្នកតំណាងរបស់ខ្ញុំ |
| ( ) លេខទូរស័ព្ទកន្លែងធ្វើការ / ( ) លេខទូរស័ព្ទសម្រាប់ផ្ញើសារ | លេខទូរស័ព្ទរបស់មេធាវី ឬរបស់អ្នកតំណាងរបស់ខ្ញុំ |
| ( ) លេខទូរសារ | |
| ម៉ោងល្អដើម្បីទូរស័ព្ទមកខ្ញុំ | |
| លេខទូរស័ព្ទដែលចង់ប្រើសម្រាប់សវនាការ | |

គ្មានជនណាម្នាក់, ដោយព្រោះពូជសាសន៍, ពណ៌សម្បុរ, ជាតិកំណើត, គោលជំនឿ, សាសនា, ភេទ, អាយុ, ឬពិការភាព, គួរត្រូវគេប្រកាន់រើសអើង នៅក្នុងការងារ, សេវាកម្ម, ឬទិដ្ឋភាពណាមួយនៃបណ្តាសកម្មភាពនានារបស់កម្មវិធីនេះឡើយ។ ទម្រង់នេះមានបម្រុងជូនជាទ្រង់ទ្រាយផ្សេងៗទៅតាមសេចក្តីស្នើសុំ។